**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## កិច្ចការស្រាវជ្រាវ

# ការកំណត់ចំណែកមរតកតាមមតកសាសន៍


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **សិត ញូន**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ចាំង ស៊ីណាត**


ថ្នាក់**បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**

ឆ្នាំចូលសិក្សា ២០១១

ជំនាញ **នីតិឯកជន** ជំនាន់ទី៩

ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៣


**រក្សាសិទ្ធិដោយ** Khmer Famous

**មាតិកា**

**សេចក្តីផ្តើម** ........................................ 2
**ក.ទម្រង់នៃមតកសាសន៍** ........................................ 3
ក.១. មតកសាសន៍ដោយលិខិតយថាភូត: ........................................ 3
ក.២. មតកសាសន៍ដោយលិខិតសម្ងាត់: ........................................ 4
ក.៣. មតកសាសន៍ដោយលិខិតឯកជន:........................................ 5
ក.៣. មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ: ........................................ 5
ក.៤. មតកសាសន៍របស់ជនដែលកំពុងជួបគ្រោះថ្នាក់ដល់អាយុជីវិត: ........................................ 6
ក.៥. មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង:........................................ 6
ក.៦. មតកសាសន៍នៃជនដែលមិនអាចនិយាយបាន: ........................................ 7
**ខ.ខ្លឹមសារនៃមតកសាសន៍**........................................ 7
ខ.១. ការកំណត់ចំណែកមតិក:........................................ 8
ខ.២. ការកំណត់វិធីបែងចែក: ........................................ 8

# សេចក្តីផ្តើម

ការកំណត់ចំណែកមតិកតាមមតកសាសន៍ គឺជាមធ្យោបាយបែងចែកមតិកតាមមតកជន ក្រៅពីការកំណត់របស់ច្បាប់ ប៉ុន្តែមតកជន មិនអាចកំណត់វិធីបែងចែកដែលមានលក្ខណៈប៉ះពាល់ដល់ភាគបម្រុងដែលជាសិទ្ធិរបស់ជនដែលបានសន្មត់ថាជាសន្តតិជននោះឡើយ។ លើសពីនេះទៅទៀត ការកំណត់ចំណែកមតិកនេះ ត្រូវតែមានលក្ខណៈសមស្របចំពោះបទបញ្ញត្តិនៃច្បាប់ផងដែរ ដូចជា ការផ្តាច់មតិកពីសន្តតិជន តាមមតកសាសន៍ត្រូវបញ្ជាក់មូលហេតុ និងមតកសាសន៍ ត្រូវកសាងឡើងតាមបញ្ញត្តិនៃច្បាប់ជាធរមាន។

ឆ្លើយតបតាមបញ្ហាចំពោះសារវ័ន្តនេះ សន្តតិកម្មតាមមតកសាន៍ត្រូវបានច្បាប់ត្រួតពិនិត្យទៅលើចំណុចសំខាន់ៗដូចជា ទម្រង់នៃមតកសាសន៍ ចំណុចដែលត្រូវសរសេរនៅក្នុងមតកសាសន៍ អានុភាពនៃមតកសាសន៍ ការលុបចោលមតកសាសន៍ និងការប្រតិបត្តិមតកសាសន៍ ជាអាទិ៍:

## ទម្រង់ និងខ្លឹមសារនៃមតកសាន៍

នីតិជន អនីតិជនដែលទទួលបានអត្តាធីនភាព អនីតិជនដែលរួចផុតពីរបបអាណាព្យាបាលសម្រាប់អនីតិជន ឬអនីតិជនដែលរួចផុតពីអំណាចមេបា អាចធ្វើមតកសាន៍បានដោយនៅពេលធ្វើបណ្តាំ ម្ចាស់បណ្តាំត្រូវមានសមត្ថភាពខាងឆន្ទៈ លើកលែងតែមតកសាសន៍ដែលធ្វើឡើងដោយជននៅក្រោមអាណាព្យាទូទៅដែលគោរពលក្ខខណ្ឌនៅក្នុងមាត្រា ១១៧៦នៃក្រមរដ្ឋប្បវេណី។

## ក.ទម្រង់នៃមតកសាសន៍

មតកសាសន៍ត្រូវធ្វើឡើងតាមទម្រង់ដែលមានកំណត់នៅក្នុងច្បាប់ ប្រសិនបើមិនគោរពទម្រង់ទេ ត្រូវចាត់ទុកជាមោឃៈ។ ដោយឡែក មតកសាសន៍មិនចុះកាលបរិច្ឆេទត្រូវចាត់ទុកថាមានសុពលភាព បើមិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលធ្វើឡើងដោយម្ចាស់បណ្តាំដូចគ្នា ហើយប្រសិនបើមតកសាសន៍ដែលគ្មានចុះកាលបរិច្ឆេទនោះមានចំនួនច្រើនច្បាប់ និងមតកសាសន៍នោះផ្ទុយគ្នា អានុភាពនៃមតកសាសន៍ទាំងនោះ ត្រូវបានកាត់បន្ថយទៅវិញទៅមក។ លើសពីនេះទៅទៀត នៅពេលធ្វើមតកសាសន៍ ត្រូវមានសាក្សី ហើយសាក្សីនៃមតកសាសន៍ដែលគ្មានលក្ខណៈសម្បត្តិមានដូចជា:

- អនីតិជន ឬជននៅក្រោមអាណាព្យាបាលធម្មតា
- ជនដែលត្រូវបានសន្មត់ថាជាសន្តតិជន អច្ច័យលាភី សហព័ទ្ធ និងញាតិលោហិតខ្សែផ្ទាល់របស់ម្ចាស់បណ្តាំ
- បើសារការីជាអ្នកធ្វើមតកសាសន៍ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និងនិយោជិតរបស់សារការីនោះ។

ទម្រង់នៃមតកសាសន៍ដែលមានកំណត់នៅក្នុងច្បាប់មានដូចខាងក្រោម:

### ក.១. មតកសាសន៍ដោយលិខិតយថាភូតៈ

+ ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំនៅចំពោះមុខសារការី
+ វត្តមានរបស់សាក្សីយ៉ាងតិចពីរនាក់
+ ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ចំពោះសារការី
+ សារការីត្រូវសរសេរអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំជាលាយល័ក្ខអក្សរ ហើយត្រូវសូត្រឲម្ចាស់បណ្តាំ និងសាក្សីស្តាប់
+ ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវចំពោះខ្លឹមសារនៃមតកសាសន៍ម្ចាស់បណ្តាំ និងសាក្សីត្រូវចុះហត្ថលេខា ហើយត្រូវបញ្ជាក់ពីឈ្មោះ អាយុ និងលំនៅ

ដ្ឋាន ប៉ុន្តែបើម្ចាស់បណ្តាំមិនចេះអក្សរ ឬមិនអាចចុះហត្ថលេខាបាន សារការីអាចធ្វើជំនួស បញ្ជាក់អំពីហេតុនោះ

+ សារការីត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។

ប្រសិនបើទម្រង់នេះ មិនត្រូវបានគោរព ឬបំពេញនោះទេ មតកសាសន៍នោះនឹងត្រូវចាត់ទុកជាមោឃៈ។

## ក.២. មតកសាសន៍ដោយលិខិតសម្ងាត់:

+ ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ
+ ម្ចាស់បណ្តាំដាក់លិខិតនោះ នៅក្នុងស្រោមបិទជិត ហើយចុះហត្ថលេខា ឬធ្វើសញ្ញាសំគាល់ ឬប្រើមធ្យោបាយផ្សេងទៀត ដែលអាចនាំឲវិនិច្ឆ័យអំពីការបើក ឬមិនបើកលិខិតនោះ
+ ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និងសាក្សីពីរនាក់ និងធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយប្រសិនបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជននោះ
+ សារការីត្រូវចុះកាលបរិច្ឆេទលើលិខិតមតកសាសន៍ដែលម្ចាស់បណ្តាំបានដាក់ និងសរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ នៅលើលិខិតដែលបានបិទជិតនោះ ហើយត្រូវចុះហត្ថលេខានៅលើលិខិតនោះ ជាមួយម្ចាស់បណ្តាំ និងសាក្សី។

ប្រសិនបើទម្រង់នេះ មិនត្រូវបានគោរព ឬបំពេញនោះទេ មតកសាសន៍ និងត្រូវចាត់ទុកជាមោឃៈ។

**ក.៣. មតកសាសន៍ដោយលិខិតឯកជនៈ**

+ ម្ចាស់បណ្ដាំសរសេរខ្លឹមសារនៃមតកសាសន៍ទាំងអស់នឹងចុះកាលបរិច្ឆេទដោយខ្លួនឯងហើយចុះហត្ថលេខាលើលិខិតនោះ។ ផ្ទុយទៅវិញ បើមតកសាសន៍ត្រូវបានសរសេរដោយអ្នកដ៏ទៃ ឬប្រើម៉ាស៊ីនដូចជាកុំព្យូទ័រជាអាទិ៍ត្រូវចាត់ជាមោឃៈ
+ ការបន្ថែម ការលុប ឬការកែប្រែផ្សេងៗ នៅក្នុងមតកសាសន៍ ពុំមានអានុភាពឡើយ បើម្ចាស់បណ្ដាំមិនបានសរសេរបន្ថែមនូវមូលហេតុនោះ និងត្រូវចុះហត្ថលេខា ផងដែរ។

មួយវិញទៀតទម្រង់មតកសាសន៍ដោយលិខិតឯកជន អាចមានស្ថានភាពពិសេសមួយចំនួនដូចជាៈ

**ក.៣. មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅៈ**

+ ជននៅក្រោមអាណាព្យាបាលទូទៅ អាចធ្វើមតកសាសន៍បាន នៅពេលខ្លួនសះស្បើយមួយរយៈឡើងវិញនូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានវេជ្ជបណ្ឌិតយ៉ាងតិចពីរនាក់
+ វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមនៅលើលិខិតនោះថា នៅពេលដែលម្ចាស់បណ្ដាំបានធ្វើមតកសាសន៍ ម្ចាស់បណ្ដាំពុំបានស្ថិតនៅក្នុងស្ថានភាពខ្វះសមត្ថភាព នៅក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីនោះទេ ហើយត្រូវចុះហត្ថលេខា ដោយបញ្ជាក់ថាខ្លួនជាវេជ្ជបណ្ឌិត ផងដែរ។

**ក.៤. មតកសាសន៍របស់ជនដែលកំពុងជួបគ្រោះថ្នាក់ដល់អាយុជីវិត:**

+ ម្ចាស់បណ្តាំដែលកំពុងជួបគ្រោះថ្នាក់ដល់អាយុជីវិតដោយសារជំងឺ ឬហេតុផ្សេងៗមានមានបំណងធ្វើមតកសាសន៍ មតកសាសន៍នោះអាចធ្វើបាន បើមានវត្តមានសាក្សីយ៉ាងតិចបីនាក់ ហើយបានប្រកាសខ្លឹមសារនៃមតកសាសន៍នោះដោយផ្ទាល់មាត់ ចំពោះជនម្នាក់នៅក្នុងចំណោមសាក្សីទាំងនោះ។

+ សាក្សីណាម្នាក់ឬបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ត្រូវដាក់ពាក្យសុំទៅតុលាការនៅក្នុងអំឡុងពេលមួយខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ដើម្បីអាចទទួលបានការបញ្ជាក់អំពីភាពត្រឹមត្រូវ

+ តុលាការ ត្រូវធ្វើការបញ្ជាក់មតកសាសន៍នោះ ប្រសិនបើយល់

  ឃើញថា មតកសាសន៍នោះចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ។

**ក.៥. មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង:**

+ ម្ចាស់បណ្តាំដែលត្រូវជាប់ឃុំឃាំងដោយសារសេចក្តីសំរេចរបស់

  តុលាការ អាចធ្វើលិខិតមតកសាសន៍បានដោយមានវត្តមាននគរបាល ឬមន្ត្រីនៃឃុំឃាំងម្នាក់នឹងសាក្សីយ៉ាងតិចពីរនាក់

+ បើម្ចាស់បណ្តាំនៅក្នុងនាវា ឬយន្តហោះអាចធ្វើមតកសាសន៍បានដោយត្រូវមានវត្តមានមេបញ្ជាការ ឬបរិបាលនាវា បុគ្គលិកម្នាក់ និងសាក្សីយ៉ាងតិចពីរនាក់

+ អាចធ្វើមតកសាសន៍ដោយផ្ទាល់មាត់

+ នគរបាល ឬមន្ត្រីនៃការឃុំឃាំង ជាអាទិ៍ ត្រូវបានបកស្រាយថា ជាសារការី

+ មតកសាសន៍នេះ ពុំមានអនុភាពឡើយ បើម្ចាស់បណ្តាំបន្តនៅរស់ក្នុងអំឡុងពេល៦ខែ គិតចាប់ពីពេលដែលខ្លួនត្រូវបានដោះលែង។

**គ.៦. មតកសាសន៍នៃជនដែលមិនអាចនិយាយបាន:**

+ ជនដែលមិនអាចនិយាយបាន អាចធ្វើមតកសាសន៍បាន ដោយម្ចាស់បណ្តាំធ្វើសេចក្តីថ្លែងការណ៍ អំពីខ្លឹមសារនៃមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬសរសេរដោយដៃផ្ទាល់ខ្លួននៅចំពោះមុខសារការី ឬសាក្សី

+ សារការី ឬបុគ្គលផ្សេងទៀត ត្រូវអានឲម្ចាស់បណ្តាំស្តាប់ ឬសាក្សីនូវខ្លឹមសារមតកសាសន៍ ក្រោយពេលសរសេរជាលាយលក្ខអក្សរអំពីខ្លឹមសារនោះ ហើយម្ចាស់បណ្តាំថ្លង់ត្រូវអានឲស្តាប់ ដោយាមានការបកប្រែពីអ្នកបកប្រែ ទៅឲម្ចាស់បណ្តាំ ឬសាក្សី

+ សារការី ឬបុគ្គលផ្សេងទៀត ត្រូវសរសេរអំពីហេតុនោះ នៅក្នុងមតកសាសន៍

– មតកសាសន៍របស់អ្នកមានសញ្ជាតិខ្មែរដែលរស់នៅបរទេស: អ្នកមានសញ្ជាតិខ្មែរដែលរស់នៅបរទេស អាចធ្វើមតកសាសន៍ដោយលិខិតយថាភូតលិខិតសម្ងាត់នៅទីកន្លែងដែលមានកុងស៊ុល ឬទូតនៃបរទេសកម្ពុជាប្រចាំនៅដោយកុងស៊ុល ឬទូតនោះ ត្រូវអនុវត្តតួនាទីជាសារការី។

## ខ.ខ្លឹមសារនៃមតកសាសន៍

ខ្លឹមសារនៃមតកសាសន៍ គឺជាចំណុចសារវ័ន្ត ដែលត្រូវដាក់បញ្ចូលនៅក្នុងលិខិតមតកសាសន៍ ឬជាចរិករបស់លិខិតមតកសាសន៍ ដែលអាចឆ្លុះបញ្ចាំងអំពីឆន្ទៈរបស់មតកជន ហេតុនេះច្បាប់បានកំណត់នូវចំណុចជាសារវ័ន្តទាំងនោះ ដូចជា ការកំណត់ចំណែកមតិក ការកំណត់វិធីបែងចែក អនុប្បទាន ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ និងចំណុចផ្សេងៗ។

## ខ.១. ការកំណត់ចំណែកមត៌កៈ

មតកជន អាចកំណត់ចំណែកមត៌ករបស់សហសន្តតិជន តាមមតកសាសន៍បាន ទោះបីជាផ្ទុយនឹងបញ្ញត្តិច្បាប់ស្តីផលប្រយោជន៍ពិសេសក៏ដោយ លើកលែងតែការកំណត់ចំណែកមត៌កនោះ បំពានភាគបម្រុង។ ផ្ទុយទៅវិញ បើមតកជនបានកំណត់ចំណែកមត៌កចំពោះសន្តតិជនតែម្នាក់ ឬច្រើននាក់ ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវធ្វើឡើងតាមគោលការណ៍នៃការសម្រួលចំណែកមត៌ក ហើយបើបំពានភាគបម្រុង ត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។ ឧទាហរណ៍: មតកជនបានបន្សល់នូវកូន០៣នាក់ ក ខ និងគ និងទ្រព្យចំនួន៩០០០ កាលនៅរស់បានធ្វើអំណោយឲកូនឈ្មោះ "ក"ចំនួន៥០០០ ហើយមតកជនធ្វើមតកសាសន៍ដែលមានខ្លឹមសារថាឲកូនឈ្មោះ"ខ"៨០០០ ហើយចំណែកនៅសល់ឲកូនដ៏ទៃទៀត។

## ខ.២. ការកំណត់វិធីបែងចែកៈ

មតកជនអាចកំណត់នូវបែងចែកតាមមតកសាសន៍ ឬ ប្រគល់អាណ្ណត្តិឲ្យតតីយជនកំណត់ ឬហាមឃាត់មិនឲ្យបែងចែកនៅក្នុងអំឡុងពេលមិនលើស០៥ឆ្នាំគិតចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម។ ឧទាហរណ៍: មតកជនមានកូន ០៣នាក់ (ក ខ និងគ)ដោយនៅក្នុងមតកសាសន៍នោះ កំណត់ជាក់អំពីវត្ថុដែលជាចំណែកមត៌ករបស់កូននីមួយៗ ដោយនៅក្នុយងមតកសាសន៍នោះ បានបញ្ជាក់ថា "ក"ជាអ្នកប្រតិបត្តិមតកសាសន៍(កូនច្បង) ហើយត្រូវគ្រប់គ្រងទ្រព្យសម្បត្តិនេះរហូតដល់ប្អូនៗមាននីតិភាព ទើបធ្វើការបែងចែកស្មើៗគ្នា ដែលមតកសាសន៍មានអនុភាពនៅថ្ងៃទី០១/០១/២០១០ ហើយប្អូនៗរបស់"ក"នឹងទទួលបាននីតិភាពទាំងអស់គ្នានៅឆ្នាំ២០១៥។ មានន័យថា"ក"មិនអាចចាត់ចែងមតកសាសន៍នេះបានទេ ទោះបី សន្តតិកម្មបានចាប់ផ្តើមហើយក៏ដោយ ក៏ត្រូវរង់ចាំរហូតប្អូនៗបានទទួលនីតិភាពផងដែរ។

ដូច្នេះបើសហព័ទ្ធរបស់មតកជន និងបុគ្គលផ្សេងៗទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយសន្តតិជន ចំណែកមត៌ករបស់សន្តតិជននឹងត្រូវមានតាមកំណត់ដូចខាងក្រោមនេះ

- បើសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ

និងកូននីមួយៗរបស់មតកជននោះនឹងត្រូវទទួលចំណែកមត៌កស្មើគ្នា។

- បើសហព័ទ្ធនិងឪពុកម្តាយរបស់មតកជនជាសន្តតិជនចំណែកមត៌ករបស់

សហព័ទ្ធត្រូវជា១ភាគ៣ឯចំណែកមត៌ករបស់មត៌ករបស់ឪពុក ម្តាយត្រូវជា២ភាគ៣។ប៉ុន្តែឪពុកឬម្តាយរបស់មតកជនតែម្នាក់នៅរស់ឪម្តាយនោះនិងសហព័ទ្ធត្រូវបានចំណែកមត៌កស្មើគ្នា។

- បើសហព័ទ្ធ និងបុព្វញាតិផ្ទាល់ក្រៅពីឪម្តាយរបស់មតកជន ឬបងប្អូនបង្កើត

របស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ ជាសន្តតិជនចំណែកមត៌ករបស់សហព័ទ្ធត្រូវជា១ភាគ២ ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសនោះ ត្រូវជា១ភាគ២។